**គម្រោងបន្ទាញបច្ចេកវិទ្យាដើម្បីបង្កើន ផលិតភាព ជុំវិញតំបន់ទន្លេសាប**

(TSTD - TA 7305-CAM)

<u>ឧបត្ថម្ភថវិកាដោយៈ</u>

រដ្ឋាភិបាលប្រទេសហ្វាំងឡង់ និង ធនាគារអភិវឌ្ឍន៍អាស៊ី

# បច្ចេកទេសចិញ្ចឹមបំប៉នមាន់សាច់



## <u>ទីតាំងទំនាក់ទំនងទិញកូនមាន់ស្រុកចិញ្ចឹម៖</u>

**ខេត្តកំពង់ចាម**

- ក្រុងសួង: ចេវ ស្រីម៉ៅ 097 613 0297
- ស្រុកជើងព្រៃ: ហួរ ប៊ុនថេង 089 468 277

**ខេត្តកំពង់ធំ**

- ស្រុកកំពង់ស្វាយ: គី សាវុធថា 012 410 321

**ខេត្តបន្ទាយមានជ័យ**

- ស្រុកមង្គលបុរី: ផាន ភាព 092 933 883

ខែ កញ្ញា ឆ្នាំ ២០១២

## សេចក្តីផ្តើម

ការចិញ្ចឹមមាន់ស្រុក ផ្តល់ប្រភពចំណូលបន្ថែមជាប្រចាំដល់គ្រួសារ ដោយចំណាយពេលទំនេរ និង ធនធានមួយចំនួនប៉ុណ្ណោះ។ ទិញកូនមាន់ស្រុកពីកន្លែងភ្ញាស់ ដែលបានគ្រប់គ្រងតាមបច្ចេកទេសត្រឹមត្រូវ អាចជួយមិនឲ្យមាន់ឈឺជម្ងឺកាចសាហាវនានា។ ពូជមាន់ក្នុងស្រុកមានការពេញនិយមពីអ្នកហូប មានតម្រូវការទីផ្សារខ្ពស់ និងងាយស្រួលលក់ (មានតម្លៃថ្លៃ) ។ តាមរយៈបច្ចេកទេសចិញ្ចឹមនេះ កូនមាន់ស្រុក ១ក្បាល (អាយុ ២១ ថ្ងៃ) ចិញ្ចឹមក្នុងរយៈពេលតែ ៨៥ថ្ងៃ អាចទទួលបានទម្ងន់ជាមធ្យម ១,២គីឡូក្រាម។ តាមបទពិសោធន៍កន្លងមក កសិករចិញ្ចឹមអាចទទួលបានប្រាក់ចំណេញសុទ្ធ ក្នុង ១គីឡូក្រាមមាន់រស់ ជាមធ្យមពី ៦០០០ ទៅ ៧០០០រៀល ។ ប្រាក់ចំណូលសរុបនឹងកើនឡើង បើកសិករចិញ្ចឹមកូនមាន់ស្រុក បំប៉នយកសាច់កាន់តែច្រើន។

## តើកូនមាន់ពូជក្នុងស្រុក តាមកសិដ្ឋានភ្ញាស់ មានគុណសម្បត្តិអ្វីខ្លះ សម្រាប់យកទៅចិញ្ចឹមបំប៉នលក់?

- កូនមាន់មានសុខភាពល្អ និងលូតលាស់លឿន
- មានអាយុពី ២១ ដល់ ៣០ថ្ងៃ និង មានទម្ងន់សមស្របសម្រាប់ចិញ្ចឹម
- មាន់ស្រុកពេញនិយមពីអ្នកបរិភោគ (ងាយស្រួលលក់)
- ចិញ្ចឹមមិនងាយឈឺ ដោយបានចាក់វ៉ាក់សាំងការពារជម្ងឺ ២-៣មុខ រួចជាស្រេច (ជម្ងឺញ៉ូវកាស កំប្ញូរ និង អុត) ។ អ្នកចិញ្ចឹមត្រូវចាក់បន្ថែម វ៉ាក់សាំងជម្ងឺអាសន្នរោគនៅពេលមាន់អាយុបាន ២ខែ។

## តើចិញ្ចឹមមាន់សាច់ដូចម្តេច ឲ្យទទួលបានជោគជ័យ?

### ១. ការសង់ទ្រុងគំរូចិញ្ចឹមបំប៉នកូនមាន់សាច់

- ធ្វើទ្រុងលើដី មិនលិចទឹក និងមានខ្យល់ចេញចូលល្អ
- ដញ្ជាំងរោងដេកយប់ ព័ទ្ធដោយរនាបឬស្សី
- បាំងសំណាញ់ចេញក្រៅចំងាយពី៣ទៅ៤ម៉ែត្រ និងចែកខ័ណ្ឌជាបន្ទប់ៗសម្រាប់មាន់ដើរខាងក្រៅ និងហាលថ្ងៃ
- ខាងក្នុងមានធ្នើរសម្រាប់មាន់ដេក ដែលមានកំពស់ពីដី ០,៧ម៉ែត្រ និងបន្ទាទទឹងធ្នើប្រវែង ០,៧ម៉ែត្រ
- ក្នុងផ្ទៃដី ១មែត្រការ៉េ (កន្លែងដេកយប់) អាចដាក់មាន់បាន ៧ ទៅ ៨ក្បាល




### ២. ស្នូកចំណី និងស្នូកទឹក

- ដាក់ស្នូកទឹក និងចំណីឲ្យគ្រប់គ្រាន់
- ស្នូកចំណី អាចច្នៃពីប៊ីដុង ឬកានជ័រតូចធំ។







## ៣. តើត្រូវជ្រើសរើសកូនមាន់របៀបណាដើម្បីឱ្យចិញ្ចឹម បានធំធាត់លឿន ?



- មានរាងល្អ ក្លៀវក្លា ជើងលឿង
- មានអាយុយ៉ាងតិច ២១ថ្ងៃ
- មិនត្រូវចិញ្ចឹមកូនមាន់មានរោមស្អិតជាប់គ្នា ហើយពោះធ្លាក់ ឬរីង និងមានពណ៌ខៀវ
- កូនមាន់បានចាក់វ៉ាក់សាំងការពារជម្ងឺធ្ងន់បានយ៉ាងតិច ២មុខ (ជម្ងឺញ៉ូវកាស និងអុតមាន់)

## ៤. តើគួររៀបចំទ្រុងមុនដាក់កូនមាន់ចិញ្ចឹមដូចម្តេច ?

- ផ្ទៃបាតទ្រុងត្រូវស្ងួតជានិច្ច
- បាចកំបោរក្នុងទ្រុង រាល់មុនដាក់មាន់ចិញ្ចឹម ១អាទិត្យ
- ក្រាលអង្កាមបាតទ្រុងកំរាស់ ១ ទៅ ២សង់ទីម៉ែត្រ





## ៥. អនាម័យការចិញ្ចឹមមាន់

- មុនដាក់មាន់ចិញ្ចឹម ឬ ក្រោយលក់មាន់ ត្រូវសំអាតទ្រុង រួចបាចទឹកកំបោរថ្មឲ្យបានពេល ១អាទិត្យ ទើបបញ្ចូលមាន់ជាថ្មី
- ដាក់មាន់ជាក្រុមតាមអាយុប្រហែលគ្នាក្នុងបន្ទប់និមួយៗ
- ដាក់ម្សៅកំបោរថ្មនៅមាត់ទ្វារចូល



ដើម្បីសំលាប់មេរោគបាតស្បែកជើងមុនចូលទ្រុងមាន់
- ផ្លាស់ប្តូរទឹកស្អាតឱ្យផឹក បានញឹកញាប់
- ត្រូវបញ្ចេញមាន់លក់ទាំងអស់ក្នុងទ្រុងជាមួយគ្នា

☠ <u>ការប្រុងប្រយ័ត្ន</u>

- ចំពោះមាន់ងាប់ដោយជម្ងឺ ត្រូវដុត ឬ កប់ចោល។
- ហាមដាច់ខាត មិនឲ្យឈ្មួញទិញមាន់ និងអ្នកដទៃចូលក្នុងទ្រុងមាន់ ឬ ក្នុងទីធ្លាចិញ្ចឹមមាន់។

## ៦. ចំណីអាហារសម្រាប់មាន់

*តើត្រូវផ្សំចំណីដូចម្តេច ដើម្បីឲ្យមាន់ធំធាត់បានលឿន និង ចំណាយថវិកាតិច ?*

- ផ្សំបញ្ចូលគ្នារវាងចំណីផ្សំស្រេច (បាវ) ចំនួន ៥០% និងចំណីដែលរកបាននៅក្នុងភូមិ ៥០% មានដូចជា៖ ស្រូវ ចុងអង្ករ កន្ទក់ ពោត (បុក ឬ កិន) ត្រកួន ស្មៅ ផ្ទីស្វិកបាស កន្ទំថេត ចកបាយទា ។ល។
- បន្ថែមម្សៅខ្ចង ខ្ទៅ លៀស ឬ សំបកក្តាម លាយក្នុងចំណីចំនួន ១ស្លាបព្រាកាហ្វេ រៀងរាល់ពី ២ ទៅ ៣ថ្ងៃម្តង។
- ត្រូវផ្តល់ចំណីឲ្យមាន់ ពី២ ទៅ ៣ ដង ក្នុង ១ថ្ងៃ



ច្របល់ចំណីចូលគ្នា

## ៧. វិធានការការពារជម្ងឺឆ្លង និងទម្លាក់ព្រូនមាន់

ជម្ងឺមាន់កាចសាហាវ រាលដាលខ្លាំង និងបណ្តាលឲ្យមាន់ងាប់ច្រើនៗ ដូច្នេះ ដើម្បីកុំឲ្យមាន់កើតជម្ងឺ ចាំបាច់ត្រូវ៖

- ចាក់វ៉ាក់សាំងការពារមុនពេលសត្វឈឺ
- ត្រូវចាក់វ៉ាក់សាំងការពារដល់មាន់ទាំងអស់ និងទៀងទាត់
- មាន់ ១ក្បាល ត្រូវផ្តល់វ៉ាក់សាំងការពារយ៉ាងតិចបំផុតឲ្យបាន ៤មុខ (ជម្ងឺញ៉ូវកាស កំប៉ូរ៉ូ អុតមាន់ និងអាសន្នរោគ)
- ត្រូវផ្តល់ថ្នាំទម្លាក់ព្រូនរៀងរាល់ ៣ខែម្តង

*កម្មវិធីចាក់វ៉ាក់សាំងការពារជម្ងឺឆ្លង និងទម្លាក់ព្រូន*




*រៀបចំដោយ:* លោក ស៊ិន ប៉ោ
អ្នកជំនាញផ្នែកបសុសត្វ (TSTD)
porsinn@gmail.com